បោះពុម្ពនៅរោងពុម្ព ទីស្ដីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ១.៥០០ ច្បាប់

តម្លៃ ២៧៥០ រៀល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៧ លេខ ៣០ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៩៩

# រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រី រៀងរាល់សប្ដាហ៍

ក

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ១១-៨-១៩៩៩ | ព្រះរាជក្រឹត្យ ជស/រកត/០៨៩៩/៥៤ អនុញ្ញាតជូនឯកឧត្តម ឌី ឈាង អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌អោយឈប់ពីមុខតំណែង ត្រឡប់ទៅបំពេញភារកិច្ចមុខតំណែងចាស់វិញ | ១៤៨៥ |


## II- រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


| | | |
|---|---|---|
| ៩-៨-១៩៩៩ | -អនុក្រឹត្យលេខ ៧១ អនក្រ.បក ស្តីពីការផ្ទេរឥណទាន | ១៤៨៦ |
| ១១-៨-១៩៩៩ | -អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពីកិច្ចដំណើរការវាយតំលៃលោហធាតុមិនរលួយបរិសុទ្ធ | ១៤៨៧ |
| ១១-៨-១៩៩៩ | -អនុក្រឹត្យលេខ ៧៣ អនក្រ.បក ស្តីពីវិសោធនកម្មមាត្រា ៦ ថ្មី នៃអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីរបៀបលេខ៥ខទាក់ព័ន្ធទៅនឹងរបបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្គូស្លាប់បាត់ខ្លួននិងពិការ | ១៤៩៥ |
| ៩-៨-១៩៩៩ | -អនុក្រឹត្យលេខ ៩៥៧ អនក្រ.តត ស្តីពីការបំពាក់គ្រឿងឥស្សរិយយសជាតិនាយនគរបាលជាតិ | ១៤៩៧ |
| ៩-៨-១៩៩៩ | -អនុក្រឹត្យលេខ ៩៥៨ អនក្រ.តត ស្តីពីការផ្លាស់ប្តូរមន្ត្រីរាជការ | ១៤៩៧ |
| ៩-៨-១៩៩៩ | -អនុក្រឹត្យលេខ ៩៥៩ អនក្រ.តត ស្តីពីការសំរួលភារកិច្ចជូនមន្ត្រីរាជការ | ១៤៩៨ |
| ១១-៨-១៩៩៩ | -អនុក្រឹត្យលេខ ៩៦០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៤៩៩ |
| ១១-៨-១៩៩៩ | -អនុក្រឹត្យលេខ ៩៦១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៥០០ |
| ១១-៨-១៩៩៩ | -អនុក្រឹត្យលេខ ៩៦២ អនក្រ.តត ស្តីពីការជូនមេដាយមាសការងារ | ១៥០១ |
| ១១-៨-១៩៩៩ | -អនុក្រឹត្យលេខ ៩៦៣ អនក្រ.តត ស្តីពីការជូនមេដាយមាសស្ថាបនាជាតិ | ១៥០២ |


### ២-សេចក្តីសំរេច


| | | |
|---|---|---|
| ១០-៨-១៩៩៩ | -សេចក្តីសំរេចលេខ ៥៥ សសរ ស្តីពីការបន្ថែមសមាសភាពសមាជិកគណៈកម្មការសិក្សាដោះស្រាយបញ្ហាតួនាទីជកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា | ១៥០៣ |

១០-៨-១៩៩៩ -សេចក្តីសំរេចលេខ ៥៥ សសរ ស្តីពីការបង្កើតក្រុមការងារសហប្រតិបត្តិការជាមួយអ្នកជំនាញច្បាប់បរទេស ដើម្បីរៀបចំនីតិវិធី សំរាប់កាត់ឧក្រិដ្ឋជនខ្មែរក្រហម ១៥០៥

## III- ការងារបណ្តាក្រសួង

### ១-និស្តិការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### ប្រកាស

១១-៨-១៩៩៩ -ប្រកាសលេខ ៣៤៧ ពណ.នពក.ប្រក ស្តីពីការត្រួតពិនិត្យការចុះបញ្ជីពាណិជ្ជកម្ម ១៥០៦

### ២-និស្តិការរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

### ប្រកាស

៩-៨-១៩៩៩ -ប្រកាសលេខ ១៥៩ កធស.ប្រក ស្តីពីការបង្កើតមន្ទីរធម្មការនិងសាសនាខេត្តឧត្តរមានជ័យ ១៥០៧

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស/រកត/០៨៩៩/៥៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានពិនិត្យរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើសុំរបស់សាមីខ្លួន និងតាមសំណូមពរចាំបាច់នៃការងារ
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៩៩

**ត្រាស់បង្គាប់**

មាត្រា ១ ._ អនុញ្ញាតជូនឯកឧត្តម នី **ឈោង** អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ អោយឈប់ពីមុខតំណែងបច្ចុប្បន្ន ហើយអោយត្រឡប់ទៅបំពេញភារកិច្ចមុខតំណែងចាស់វិញតាមខ្លឹមសារអនុក្រឹត្យលេខ ១៤៣ អនក្រ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩២ ។

មាត្រា ២ ._ បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ ._ នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ ._ ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

***

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ៧១ អនក្រ.បក
### ស្ដីពីការផ្ទេរឥណទាន

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម នស/រកម/០១៩៩/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្ដីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្ដីពីការផ្ទេរចំណូល និង ផ្ទេរឥណទានថវិកា សំរាប់ក្រសួងស្ថាប័នថ្មី
- តាមសំណើរបស់ឯកឧត្ដមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### សំរេច

**មាត្រា ១ .-** ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកា ចំនួន ១៣០០លានរៀល ( មួយពាន់បីរយលានរៀល ) ពីជំពូក ៤១ ( ចំណាយឥតព្រាងទុក ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់តូច ) របស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ សំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៩ ។

មាត្រា ២ ._ ចំណែកមាតិកាក្នុងមាត្រា ១ ខាងលើត្រូវបានអនុញ្ញាតអោយប្រើប្រាស់ សំរាប់តភ្ជាប់បណ្តាញទូរស័ព្ទ អគ្គិសនី និង ទឹក ចូលទីតាំងអគារ ទីស្តីការក្រសួងវប្បធម៌ និង វិចិត្រសិល្បៈថ្មី ។

មាត្រា ៣ . រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី០៩ ខែ សីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★ ★ ★

## អនុក្រឹត្យលេខ ៧២ អនក្រ.បក
## ស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលបានប្រកាសឲ្យប្រើច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៩

## សំរេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

មាត្រា ១._ អនុក្រឹត្យនេះមានគោលបំណង ៖

-កំណត់ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន លើរាល់គំរោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈ ហើយត្រូវបានពិនិត្យ និងវាយតំលៃដោយ ក្រសួងបរិស្ថានមុន ដាក់ជូនរាជរដ្ឋាភិបាលសំរេច

-កំណត់ប្រភេទ និងទំហំគំរោង សកម្មភាពដែលស្នើឡើងព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការទាំងឯកជន ទាំងសាធារណៈ ដែលត្រូវវាយតំលៃហេតុប៉ះពាល់បរិស្ថាន ។

-បំផុសឲ្យមានការចូលរួមពីសាធារណជន ក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថានព្រមទាំងទទួលយកមតិ យោបល់ អោយយកទៅពិចារណា ក្នុងកិច្ចដំណើរការអនុម័តគំរោង ។

មាត្រា ២ ._ អនុក្រឹត្យនេះ អាចអនុវត្តចំពោះគំរោងដែលស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ ដែលជាបុគ្គលឯកជន ជាក្រុមហ៊ុនឯកជន ជាក្រុមហ៊ុនចំរុះរដ្ឋ ឬជាក្រុមហ៊ុនរដ្ឋជាក្រសួង-ស្ថាប័នរដ្ឋ ដែលមានចែងនៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ លើកលែងតែគំរោងដែលមានលក្ខណៈពិសេស និងចាំបាច់បន្ទាន់ ដែលសំរេចដោយរាជរដ្ឋាភិបាល ។

## ជំពូកទី ២

## ស្ថាប័នទទួលខុសត្រូវ

មាត្រា ៣ ._ ក្រសួងបរិស្ថាន មានភារកិច្ច ៖

ក-ពិនិត្យ និងវាយតំលៃលើ របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ

ខ-តាមដាន ឃ្លាំមើល និងចាត់វិធានការ ឲ្យម្ចាស់គំរោងប្រតិបត្តិតាម ផែនការគ្រប់គ្រងបរិស្ថានក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិ និងបញ្ចប់គំរោង ដូចមានចែងក្នុង របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលបានអនុម័តរួច ។

មាត្រា ៤ ._ ស្ថាប័ន និងក្រសួង ដែលមានសិទ្ធិអនុម័តលើគំរោង មានភារកិច្ច ពិនិត្យ និងសំរេចលើគំរោងដូចមានចែងក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ដែលក្រសួងបរិស្ថានបានពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ។

មាត្រា ៥ ._ អាជ្ញាធរខេត្ត-ក្រុង ដែលមានសិទ្ធិអនុម័តលើគំរោង ខេត្ត-ក្រុង មានភារកិច្ច ៖

-បញ្ជូននូវរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន នៃគំរោងដែលជាបុគ្គលឯកជនជាក្រុមហ៊ុនឯកជន ជាក្រុមហ៊ុនចំរុះរដ្ឋ ឬជាក្រុមហ៊ុនរដ្ឋ ទៅមន្ទីរបរិស្ថានខេត្ត-ក្រុង

-ពិនិត្យ និងសំរេចលើគំរោង បន្ទាប់ពីបានពិចារណាលើយោបល់របស់មន្ទីរ បរិស្ថានថ្នាក់ខេត្ត-ក្រុង ដែល ក្រសួងបរិស្ថានបានប្រគល់សិទ្ធជូន ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

## ជំពូកទី ៣

## តម្រូវការវាយតំលៃហេតុប៉ះពាល់បរិស្ថាន សំរាប់គំរោងស្នើសុំ

មាត្រា ៦ ._ ម្ចាស់គំរោងត្រូវធ្វើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ចំពោះគំរោងដែលតម្រូវឲ្យមានការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដូចមានចែងក្នុងឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

មាត្រា ៧ ._ ម្ចាស់គំរោង ត្រូវដាក់ពាក្យសុំពិនិត្យ របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និងរបាយការណ៍សិក្សាបុរេលទ្ធភាពទៅក្រសួងបរិស្ថាន ។

មាត្រា ៨ ._ ម្ចាស់គំរោងត្រូវដាក់ពាក្យសុំពិនិត្យរបាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ និងរបាយការណ៍សិក្សាលទ្ធភាពទៅក្រសួងបរិស្ថាន ចំពោះគំរោងដែលអាចបង្កហេតុប៉ះពាល់បរិស្ថានធ្ងន់ធ្ងរ ដល់ធនធានធម្មជាតិ អេកូស៊ីស្តែម សុខភាព និងសុខុមាលភាពសាធារណៈ ។

មាត្រា ៩ ._ ម្ចាស់គំរោងត្រូវដាក់ពាក្យសុំពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដូចមានចែងក្នុងមាត្រា៧ និងមាត្រា៨ ទៅមន្ទីរបរិស្ថាន ខេត្ត-ក្រុង ចំពោះគំរោងថ្នាក់ ខេត្ត-ក្រុង ។

មាត្រា ១០ ._ គោលការណ៍ណែនាំ ស្តីពីការធ្វើរបាយការណ៍ វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងរបាយការណ៍ វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

មាត្រា ១១ ._ ម្ចាស់គំរោងត្រូវបង់ថ្លៃសេវាការងារ សំរាប់ការពិនិត្យរបាយការណ៍ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការតាមដាន ត្រួតពិនិត្យ ការអនុវត្តគំរោង ។ ថ្លៃសេវាការងារនេះត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រសួងបរិស្ថាន ដែលត្រូវបញ្ចូលក្នុងថវិកាជាតិ ។

មាត្រា ១២ ._ ម្ចាស់គំរោងត្រូវវិភាគទានចូលក្នុងមូលនិធិការពារបរិស្ថាន សំរាប់កិច្ចការពារបរិស្ថាន ដូចមានចែងក្នុងមាត្រា ១៩ ជំពូកទី៨ នៃច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

មាត្រា ១៣ ._ ពាក្យសុំត្រូវបំពេញដោយម្ចាស់គំរោង និងត្រូវផ្តល់ជូនទៅក្រសួងបរិស្ថាន ចំពោះគំរោងថ្នាក់ក្រសួង ស្ថាប័ន និងត្រូវផ្តល់ជូនទៅមន្ទីរបរិស្ថានខេត្ត-ក្រុង ចំពោះគំរោងថ្នាក់ ខេត្ត-ក្រុង ។

## ជំពូកទី ៤

## បែបបទនៃកិច្ចដំណើរការ ពិនិត្យ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន សំរាប់គំរោងស្នើសុំ

មាត្រា ១៤ ._ ម្ចាស់គំរោងត្រូវរៀបចំ និងបញ្ជូនរបាយការណ៍ ដូចមានចែងក្នុងមាត្រា៧ ទៅក្រសួងបរិស្ថាន និងផ្តល់ព័ត៌មានគំរោង ទៅស្ថាប័នអនុម័តគំរោង ។

មាត្រា ១៥ ._ ក្រសួងបរិស្ថានត្រូវពិនិត្យរបាយការណ៍ ដូចមានចែងក្នុងមាត្រា ១៤ ព្រមទាំងចាត់បញ្ជូន យោបល់ និងសំណើទៅម្ចាស់គំរោង និងស្ថាប័នអនុម័តគំរោងក្នុងរយៈពេល ៣០ ថ្ងៃ គិតថ្ងៃធ្វើការ ចាប់ពីថ្ងៃដែលក្រសួងបានទទួលរបាយការណ៍សិក្សាលទ្ធភាព និងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ពីម្ចាស់គំរោង ។

មាត្រា ១៦ ._ ក្នុងករណីដែលក្រសួងបរិស្ថាន តម្រូវឲ្យមានរបាយការណ៍ វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ម្ចាស់គំរោងត្រូវរៀបចំ និងបញ្ជូនរបាយការណ៍ ដូចមានចែងក្នុងមាត្រា ៨ ទៅក្រសួងបរិស្ថាន ជាមួយនឹងការដាក់ពាក្យសុំវិនិយោគទៅស្ថាប័នអនុម័តគំរោង ។

មាត្រា ១៧ ._ ក្រសួងបរិស្ថាន ត្រូវពិនិត្យរបាយការណ៍ ដូចមានចែងក្នុងមាត្រា ១៦ ព្រមទាំងចាត់បញ្ជូនយោបល់ និងសំណើទៅម្ចាស់គំរោង និងស្ថាប័នអនុម័តគំរោងក្នុងរយៈពេល ៣០ ថ្ងៃ គិតថ្ងៃធ្វើការ ចាប់ពីថ្ងៃ ដែលក្រសួងបានទទួលរបាយការណ៍សិក្សាលទ្ធភាព និង របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ពីម្ចាស់គំរោង ។

**មាត្រា ១៨ .**_ ក្នុងករណី ក្រសួងបរិស្ថានពុំបានឆ្លើយតបតាមពេលវេលា ដូចមានចែងក្នុងមាត្រា ១៥ និងមាត្រា១៧ នោះ ស្ថាប័នអនុម័តគម្រោងអាចចាត់ទុកថា គម្រោងនោះត្រូវបានបំពេញតាម តម្រូវការ នៃអនុក្រឹត្យនេះ ។

**មាត្រា ១៩ .**_ ក្នុងសមត្ថកិច្ច ជាស្ថាប័នអនុម័តគម្រោងផង និងជាម្ចាស់គម្រោងផងនោះ ម្ចាស់គម្រោងត្រូវមានភារកិច្ច អនុវត្តតាមកិច្ចដំណើរការ ដូចមានចែងក្នុងជំពូកទី៣ និងជំពូកទី៤ នៃអនុក្រឹត្យនេះ ។

**មាត្រា ២០ .**_ មុនចាប់ដំណើរការអនុវត្តគម្រោង ម្ចាស់គម្រោងត្រូវមានលិខិតឯកភាពពីក្រសួងបរិស្ថានលើ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់ បរិស្ថានពេញលេញ ។

## ជំពូកទី ៥
## បែបបទនៃកិច្ចដំណើរការ ពិនិត្យ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន
## ចំពោះសកម្មភាពមានស្រាប់

**មាត្រា ២១ .**_ ក្នុងរយៈពេលយ៉ាងយូរ ០១ ឆ្នាំ បន្ទាប់ពី អនុក្រឹត្យនេះចូលជាធរមាន ម្ចាស់កម្មសិទ្ធិ ឬម្ចាស់ទទួល ខុសត្រូវ ត្រូវរៀបចំធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងដាក់ពាក្យសុំពិនិត្យ របាយការណ៍នេះ មកក្រសួងបរិស្ថាន ចំពោះសកម្មភាពមានស្រាប់ និងកំពុងដំណើរការ ដែល បានទទួលការអនុម័តពីថ្នាក់ក្រសួង-ស្ថាប័ន ។

**មាត្រា ២២ .**_ ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ពេញលេញ យ៉ាងយូរ ៦ ខែ ទៅតាមតម្រូវការដែលមានចែងក្នុងជំពូកទី៣ និងជំពូកទី៤ នៃ អនុក្រឹត្យនេះ ក្នុងករណីដែលក្រសួងបរិស្ថាន បានពិនិត្យឃើញថាសកម្មភាពដែលមានស្រាប់ និង កំពុងដំណើរការ តម្រូវឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

**មាត្រា ២៣ .**_ ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ដែលមានចែងក្នុង របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្នុងរយៈពេល ៦ ខែ គិតចាប់តាំងពីថ្ងៃ ដែលក្រសួង បរិស្ថានបានចេញសេចក្ដីជូនដំណឹងថា របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន បានបំពេញ តាមតម្រូវការ នៃអនុក្រឹត្យនេះ ។

**មាត្រា ២៤ .**_ ក្នុងរយៈពេលយ៉ាងយូរ ០២ ឆ្នាំ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ម្ចាស់កម្មសិទ្ធិ ឬម្ចាស់ទទួល ខុសត្រូវ ត្រូវរៀបចំធ្វើរបាយការណ៍វាយតម្លៃប៉ះពាល់បរិស្ថានដំបូង និងដាក់ពាក្យសុំពិនិត្យរបាយ ការណ៍នេះ មកមន្ទីរបរិស្ថានខេត្ត-ក្រុង ចំពោះសកម្មភាពមានស្រាប់ និងកំពុងដំណើរការដែលបាន ទទួលការអនុម័តពីថ្នាក់ ខេត្ត-ក្រុង ។

**មាត្រា ២៥ .**_ ម្ចាស់កម្មសិទ្ធិ ឬម្ចាស់ទទួលខុសត្រូវ ត្រូវរៀបចំរបាយការណ៍ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ពេញលេញ យ៉ាងយូរ ៦ ខែ ទៅតាមតម្រូវការដែលមានចែងក្នុងជំពូកទី ៣ និងជំពូកទី៤ នៃ អនុក្រឹត្យនេះក្នុងករណីដែលមន្ទីរបរិស្ថានខេត្ត-ក្រុង ពិនិត្យឃើញថា សកម្មភាពដែលមានស្រាប់ និង កំពុងដំណើរការតម្រូវឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

មាត្រា ២៦ ._ ម្ចាស់កម្មសិទ្ធិ ឬម្ចាស់ទទួលខុសត្រូវ ត្រូវអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ដែលមានចែងក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននោះ ក្នុងរយៈពេល៦ ខែ គិតចាប់តាំងពីថ្ងៃដែល មន្ទីរបរិស្ថានខេត្ត-ក្រុង បានចេញសេចក្តីជូនដំណឹងថា របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន បានបំពេញតាមតម្រូវការនៃអនុក្រឹត្យនេះ ។

## ជំពូកទី ៦

## ល័ក្ខខ័ណ្ឌ នៃការអនុម័តគំរោង

មាត្រា ២៧ ._ ស្ថាប័នអនុម័តគំរោង ត្រូវណែនាំម្ចាស់គំរោង ឬម្ចាស់កម្មសិទ្ធិ ឲ្យអនុវត្តតាមផែនការគ្រប់គ្រងបរិស្ថាននៃគំរោង ដូចបានរៀបរាប់ក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលបានអនុម័តដោយក្រសួងបរិស្ថាន ។

មាត្រា ២៨ ._ ក្រសួងបរិស្ថាន ត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធចេញបញ្ជាឲ្យផ្អាកសកម្មភាព ចំពោះម្ចាស់គំរោង ឬម្ចាស់កម្មសិទ្ធិណា ដែលពុំបានអនុវត្តតាមផែនការគ្រប់គ្រងបរិស្ថាននៃគំរោង ដូចបានចែងក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលបានឯកភាពរួចហើយ ។

## ជំពូកទី ៧

## ទោសប្បញ្ញត្តិ

មាត្រា ២៩ ._ ម្ចាស់គំរោង ឬម្ចាស់កម្មសិទ្ធិដែលខកខានមិនបានផ្តល់ ឬបកស្រាយខុសនូវព័ត៌មាន ឬមិនបានអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ដូចបានពិពណ៌នានៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬបំពាននឹងបទប្បញ្ញត្តិណាមួយ នៃអនុក្រឹត្យនេះត្រូវផ្តន្ទាទោស ដូចមានចែងក្នុងមាត្រា ២០/២១/២២/២៣ និងមាត្រា២៥ ជំពូកទី៩ នៃច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

មាត្រា ៣០ ._ កំណត់ហេតុ និងការធ្វើបណ្តឹងចំពោះជនទាំងឡាយណា ដែលបានប្រព្រឹត្តខុស ឬពុំអនុវត្តតាមមាត្រាណាមួយ នៃអនុក្រឹត្យនេះ គឺជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។

មាត្រា ៣១ ._ មន្ត្រីបរិស្ថានរូបណា ដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជា របស់ក្រសួង ឬឃុបឃិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសំរួលក្នុងការប្រព្រឹត្តិបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោស ផ្នែករដ្ឋបាល ឬនឹងត្រូវជាប់ចោទប្រកាន់ចំពោះមុខតុលាការ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

មាត្រា ៣២ ._ បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងស្ថាប័នពាក់ព័ន្ធ ព្រមទាំងមន្ត្រីរាជការក្រសួងបរិស្ថាន ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៣៤ .-** អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**ម៉ុក ម៉ារ៉េត**

* * *

**តារាងឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៧២ អនក្រ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩**

**ចំណាត់ថ្នាក់គំរោងត្រូវធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន**

***

| ល.រ | ប្រភេទអាជីវកម្ម | ទំហំ |
|---|---|---|
| ១ | **វិស័យឧស្សាហកម្ម** | |
| ១.១ | **ផ្នែក ស្បៀង , ម្ហូបអាហារ ភេសជ្ជៈ និង ថ្នាំជក់** | |
| ១.១.១ | មូលដ្ឋានកែច្នៃម្ហូបអាហារ និងដាក់កំប៉ុង | ≥ ៥០០ តោន / ឆ្នាំ |
| ១.១.២ | មូលដ្ឋានផលិតភេសជ្ជៈ - ទឹកផ្លែឈើគ្រប់ប្រភេទ | ≥ ១.៥០០ លីត្រ / ថ្ងៃ |
| ១.១.៣ | មូលដ្ឋានផលិតដំណាប់ផ្លែឈើ | ≥ ៥០០ តោន / ឆ្នាំ |
| ១.១.៤ | មូលដ្ឋានផលិតទឹកក្រូច | គ្រប់ទំហំ |
| ១.១.៥ | មូលដ្ឋានផលិតស្ករ | គ្រប់ទំហំ |
| ១.១.៦ | មូលដ្ឋានផលិតស្រាបៀរ - អាល់កុល | គ្រប់ទំហំ |
| ១.១.៧ | មូលដ្ឋានផលិតទឹកស្អាត | ≥១០.០០០ អ្នកប្រើប្រាស់ |
| ១.១.៨ | មូលដ្ឋានផលិតបារី | ≥ ១០.០០០ កញ្ចប់ / ថ្ងៃ |
| ១.១.៩ | មូលដ្ឋានផលិត កែច្នៃស្លឹកថ្នាំជក់ | ≥ ៣៥០ តោន / ថ្ងៃ |
| ១.១.១០ | មូលដ្ឋានផលិតស្ករស | ≥ ៣.០០០ តោន / ឆ្នាំ |
| ១.១.១១ | មូលដ្ឋានកិនស្រូវ និងគ្រាប់ធញ្ញជាតិ | ≥ ៣.០០០ តោន / ឆ្នាំ |
| ១.១.១២ | មូលដ្ឋានផលិតទឹកត្រី ស៊ីអ៊ីវ គៀវ ម្ទេស ម៉ង់ពោះ | ≥ ៥០០.០០០ លីត្រ / ឆ្នាំ |

| | | |
|---|---|---|
| **១.២** | **ផ្នែកវាយនភណ្ឌ , សំលៀកបំពាក់ , និង ផលិតផលស្បែក** | |
| ១.២.១ | រោងចក្រតម្បាញ - ជ្រលក់ពណ៌ | គ្រប់ទំហំ |
| ១.២.២ | រោងចក្រកាត់ដេរ បោកគក់ បោះពុម្ព ជ្រលក់ពណ៌ | គ្រប់ទំហំ |
| ១.២.៣ | រោងចក្រសំលាប់ស្បែក កែច្នៃស្បែក ធ្វើការស្បែកជាគ្រឿង | គ្រប់ទំហំ |
| ១.២.៤ | រោងចក្រផលិតអេប៉ុង កៅស៊ូអូត | គ្រប់ទំហំ |
| **១.៣** | **ផ្នែកផលិតផលពីឈើ** | |
| ១.៣.១ | រោងចក្រក្តារបន្ទះ | ≥ ១០០.០០០ម³ / ឆ្នាំឈើមូល |
| ១.៣.២ | មូលដ្ឋានផលិតក្តារបន្ទះស្តើង | ≥ ១.០០០ម³ / ឆ្នាំ ឈើមូល |
| ១.៣.៣ | រោងចក្រអារឈើ | ≥ ៥០.០០០ម³ / ឆ្នាំឈើមូល |
| **១.៤** | **ផ្នែកផលិតក្រដាស** | |
| ១.៤.១ | រោងចក្រផលិតក្រដាស | គ្រប់ទំហំ |
| ១.៤.២ | រោងចក្រផលិតម្សៅក្រដាស និងកែច្នៃក្រដាស | គ្រប់ទំហំ |
| **១.៥** | **ផ្នែកគីមី ផលិតផលពីកៅស៊ូ និងប្លាស្ទិក** | |
| ១.៥.១ | រោងចក្រប្លាស្ទិក | គ្រប់ទំហំ |
| ១.៥.២ | រោងចក្រកៅស៊ូកង់ និងពោះវៀនកង់គ្រប់ប្រភេទ | ≥ ៥០០ តោន / ឆ្នាំ |
| ១.៥.៣ | រោងចក្រកៅស៊ូក្រែប | ≥១.០០០ តោន / ឆ្នាំ |
| ១.៥.៤ | រោងចក្រផលិតអាគុយ និងថ្មពិល | គ្រប់ទំហំ |
| ១.៥.៥ | រោងចក្រគីមី | គ្រប់ទំហំ |
| ១.៥.៦ | រោងចក្រផលិតជីគីមី | ≥ ១០.០០០ តោន / ឆ្នាំ |
| ១.៥.៧ | រោងចក្រផលិតថ្នាំសំលាប់សត្វល្អិត | គ្រប់ទំហំ |
| ១.៥.៨ | រោងចក្រផលិតថ្នាំលាបគ្រប់ប្រភេទ | គ្រប់ទំហំ |
| ១.៥.៩ | រោងចក្រគីមីប្រេងកាត | គ្រប់ទំហំ |
| ១.៥.១០ | រោងចក្រផលិតម្សៅសាប៊ូ សាប៊ូដុំ សាប៊ូទឹក | គ្រប់ទំហំ |
| **១.៦** | **ផ្នែកផលិតផលពីរ៉ែ មិនមែនជាលោហៈ** | |
| ១.១.៦ | រោងចក្រស៊ីម៉ង់ត៍ | គ្រប់ទំហំ |
| ១.៦.២ | រោងចក្រចំរាញ់ប្រេងកាត | គ្រប់ទំហំ |
| ១.៦.៣ | រោងចក្រផលិតឧស្ម័ន | គ្រប់ទំហំ |
| ១.៦.៤ | សំណង់បណ្តូរប្រេង និងឧស្ម័ន | ≥ ២ គ.ម |
| ១.៦.៥ | កន្លែងស្តុកប្រេងឥន្ធនៈសំរាប់ចែកចាយ | ≥ ១.០០០.០០០ លីត្រ |
| ១.៦.៦ | ស្ថានីយ៍ប្រេងឥន្ធនៈ | ≥ ២០.០០០ លីត្រ |

| | | |
|---|---|---|
| ១.៦.៧ | ការធ្វើអាជីវកម្មរ៉ែ | គ្រប់ទំហំ |
| ១.៦.៨ | រោងចក្រផលិតកែវ គ្រប់ប្រភេទ | គ្រប់ទំហំ |
| ១.៦.៩ | មូលដ្ឋានផលិតឥដ្ឋក្បឿង | ≥ ១៥០.០០០ ដុំ / ខែ |
| ១.៦.១០ | មូលដ្ឋានផលិតឥដ្ឋក្រាល ឥដ្ឋការ៉ូ | ≥ ៨០.០០០ ដុំ / ខែ |
| ១.៦.១១ | រោងចក្រផលិតស៊ីម៉ង់ត៍ | គ្រប់ទំហំ |
| ១.៦.១២ | មូលដ្ឋានផលិតគ្រឿងសំណង់ពេជ្រ | ≥ ៥០០ តោន / ខែ |
| ១.៦.១៣ | រោងចក្រផលិតខ្លាញ់គោ ប្រេងអ៊ីស៊ីន | គ្រប់ទំហំ |
| ១.៦.១៤ | ការសិក្សាស្រាវជ្រាវអាជីវកម្មរ៉ែប្រេងកាត ( ការខួងឆាគព្យួង, ការធ្វើ ឲ្យរញ្ជួយដី ) | គ្រប់ទំហំ |
| **១.៧** | **ផ្នែកឧស្សាហកម្មលោហៈ មូលដ្ឋាន** | |
| ១.៧.១ | រោងចក្រផលិតគ្រឿងយន្ត | គ្រប់ទំហំ |
| ១.៧.២ | រោងចក្រតំឡើងគ្រឿងយន្ត | គ្រប់ទំហំ |
| ១.៧.៣ | សហគ្រាសជួសជុលគ្រឿងយន្ត និងនាវា | គ្រប់ទំហំ |
| **១.៨** | **ផ្នែកឧស្សាហកម្មកែច្នៃលោហៈ** | |
| ១.៨.១ | រោងចក្រកែច្នៃលោហៈគ្រប់ប្រភេទ ដែកគោល លួសបន្លា សំណាញ់ | ≥ ៣០០ តោន / ខែ |
| ១.៨.២ | រោងចក្រស្លដែក ដែកថែប អាលុយមីនីញ៉ូម | គ្រប់ទំហំ |
| ១.៨.៣ | រោងចក្រស្លលោហៈគ្រប់ប្រភេទ | គ្រប់ទំហំ |
| **១.៩** | **ផ្នែកឧស្សាហកម្មផ្សេងៗ** | |
| ១.៩.១ | មូលដ្ឋានកែច្នៃសំណល់ ដុតសំណល់ | |
| ១.៩.២ | មូលដ្ឋានសំអាតទឹកសំអុយ | |
| ១.៩.៣ | រោងចក្រអគ្គិសនី | ≥ ៥ MW |
| ១.៩.៤ | រោងចក្រវារីអគ្គិសនី | ≥ ១ MW |
| ១.៩.៥ | រោងចក្រផលិតសំឡី | ≥ ១៥ តោន / ខែ |
| ១.៩.៦ | រោងចក្រផលិតចំណីសត្វ | ≥ ១០.០០០ តោន / ឆ្នាំ |
| **២** | **វិស័យកសិកម្ម** | |
| ២.១ | ព្រៃសម្បទាន | ≥ ១០.០០០ ហិចតា |
| ២.២ | អាជីវកម្មព្រៃគប់ | ≥ ៥០០ ហិចតា |
| ២.៣ | ផ្ទៃដីដែលមានព្រៃឈើ | ≥ ៥០០ ហ.ត |
| ២.៤ | ផ្ទៃដីដំណាំកសិកម្ម ឧស្សាហកម្ម | ≥ ១០.០០០ ហ.ត |

| | | |
|---|---|---|
| ២.៥ | ផ្ទៃដីពាក់ទឹក និងដីតំបន់ឆ្នេរ | គ្រប់ទំហំ |
| ២.៦ | ប្រព័ន្ធស្រោចស្រព | ≥ ៥.០០០ ហ.ត |
| ២.៧ | ប្រព័ន្ធដោះទឹក | ≥ ៥.០០០ ហ.ត |
| ២.៨ | ដែនេសាទ | គ្រប់ទំហំ |
| ៣- | **វិស័យទេសចរណ៍** | |
| ៣.១ | តំបន់ទេសចរណ៍ | ≥ ៥០ ហ.ត |
| ៣.២ | ទីលានវាយកូនគោល | ≥ ១៨ រន្ធ |
| ៤ | **ហេដ្ឋារចនាសម្ព័ន្ធ** | |
| ៤.១ | ការអភិវឌ្ឍន៍ទីក្រុង | គ្រប់ទំហំ |
| ៤.២ | តំបន់ឧស្សាហកម្ម | គ្រប់ទំហំ |
| ៤.៣ | សំណង់ស្ពានធំៗ | ទ្រទំងន់ ≥ ៣០ តោន |
| ៤៤ | សំណង់អាគារ | កំពស់ ≥ ១២ម.ឬ ក្រឡាផ្ទៃ ៨.០០០ ម^២^ |
| ៤.៥ | ភោជនីយដ្ឋាន | ≥ ៥០០ កៅអី |
| ៤.៦ | សំណង់សណ្ឋាគារ | ≥ ៦០ បន្ទប់ |
| ៤.៧ | សំណង់សណ្ឋាគារតំបន់ឆ្នេរ | ≥ ៤០ បន្ទប់ |
| ៤.៨ | សំណង់ផ្លូវជាតិ | ≥ ១០០ គ.ម |
| ៤.៩ | សំណង់ផ្លូវដែក | គ្រប់ទំហំ |
| ៤.១០ | សំណង់កំពង់ផែ | គ្រប់ទំហំ |
| ៤.១១ | សំណង់អាកាសយានដ្ឋាន | គ្រប់ទំហំ |
| ៤.១២ | ការបូមភក់ - ល្បប់ | ≥ ៥០.០០០ ម^៣^ |
| ៤.១៣ | កន្លែងចាក់សំរាមទីក្រុង | ≥ ប្រជាជន ២០០.០០០ នាក់ |

★ ★ ★

**អនុក្រឹត្យលេខ ៧៣ អនក្រ.បក**
**ស្តីពីវិសោធនកម្មមាត្រា៦ ថ្មី នៃអនុក្រឹត្យលេខ ៣៨អនក្រ.បក ចុះថ្ងៃទី២១**
**ខែមេសា ឆ្នាំ១៩៩៩ ត្រង់ចំណុចលេខ៥ ខ ពាក់ព័ន្ធទៅនឹងរបបឧបត្ថម្ភ**
**ចំពោះយោធិន ពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៧/នស/៩៤ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីរបបសោធននិវត្តន៍ និងសោធនកាកប៉ាវចំពោះបុគ្គលិកយោធា សំរាប់យោធិន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- យោងអនុក្រឹត្យលេខ ៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៦ របស់រាជរដ្ឋាភិបាល ស្តីពីរបបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បន្តភ្ជាប់ បាត់ខ្លួន និងពិការ
- យោងអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពីការកែតម្រូវមាត្រាអនុក្រឹត្យលេខ ៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៦
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

មាត្រា ១ . ចំណុចលេខ ៥ នៃអក្សរ " ខ " ក្នុងមាត្រា ៦ ថ្មី នៃអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៩ ត្រូវបានកែតម្រូវដូចតទៅ ៖

-ចំពោះយោធិនពិការ ដែលនៅបំពេញការងារ នៅពេលគ្រប់លក្ខខណ្ឌសម្រាប់ចូលនិវត្តន៍ ត្រូវផ្ទេរទៅក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ដើម្បីដោះស្រាយប្រាក់សោធននិវត្តន៍វិញ ។

មាត្រា ២ ._ បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងនិងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ,ថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៩៩

បានជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី
សហរដ្ឋមន្ត្រីក្រសួងការពារជាតិ
ហត្ថលេខា
ទៀ បាញ់ ស៊ីសុវត្ថិ សិរីរត្ន

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

★ ★ ★

**អនុក្រឹត្យលេខ ៤៥៧ អនក្រ.តត**

**ស្ដីពីការបំពាក់ឋានន្តរសក្តិនាយនគរបាលជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

មាត្រា ១.- ត្រូវបានបំពាក់ឋានន្តរសក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូនលោក **ឈុះ ស្វាយ** អនុប្រធានទី១ អគ្គនាយកដ្ឋានបុគ្គលិក នៃក្រសួងមហាផ្ទៃ ។

មាត្រា ២.- ទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★ ★ ★

**អនុក្រឹត្យលេខ ៤៥៨ អនក្រ.តត**

**ស្ដីពីការផ្លាស់ប្តូរមន្ត្រីរាជការ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សម្តេចរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១ .-** ត្រូវបានផ្លាស់ប្តូរលោក ស៊ សារឹម អភិបាលរងក្រុងកេប អោយមកបំរើការងារនៅតាមកាកខេត្តកំពង់ធំ ដោយរក្សាឋានៈដដែល ។

**មាត្រា ២ .-** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .-** ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួងស្ថាប័ន ខេត្ត-ក្រុង ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៩ ខែសីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★ ★ ★

**អនុក្រឹត្យលេខ ៨៥៩ អនក្រ.តត**

**ស្តីពីការសំរួលភារកិច្ចជូនមន្ត្រីរាជការ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សម្តេចរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ ._ ត្រូវបានតំឡើងភារកិច្ចលោក សេង តេនះ អភិបាលរងខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដោយមកទទួលភារកិច្ចថ្មី ដែលនឹងត្រូវតែងតាំងដោយក្រសួងមហាផ្ទៃ តាមការស្នើសុំរបស់ខ្លួនដែរ ។

មាត្រា ២ ._ បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ ._ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៩ ខែសីហា ឆ្នាំ១៩៩៩
នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
**ហ៊ុន សែន**

*****

## អនុក្រឹត្យលេខ ៤៦០ អនក្រ.តត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

★ ★ ★

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសឱ្យប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អគ្គលេខាធិការរងរាជរដ្ឋាភិបាល

សំរេច

មាត្រា ១ ._ ត្រូវបានប្រគល់ **មេដាយមាស ស្ថាបនាជាតិ** ជូនលោកឧកញ៉ា **សុខ គង់** អគ្គនាយកក្រុមហ៊ុនវិនិយោគ សូគីម៉ិច កម្ពុជា ដែលបានធ្វើអំណោយជា តុ កៅអីម្ហូបសំរាប់ ធ្វើអំពីឈើ ប្រណិតប្រកបដោយក្បាច់ចម្លាក់វិចិត្រ សំរាប់ដាក់ក្នុងសាលប្រជុំគណៈរដ្ឋមន្ត្រី មានតម្លៃជាទឹកប្រាក់ចំនួន ៣៥.០០០ ដុល្លារអាមេរិក ។

**មាត្រា ២ .**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ជាបន្ទាន់ ។

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★ ★ ★

## អនុក្រឹត្យលេខ ៤៦១ អនក្រ.តត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអភិបាលរាជធានីភ្នំពេញ

### សំរេច

**មាត្រា ១ .**_ ត្រូវបានប្រគល់ **មេដាយមាស ស្ថាបនាជាតិ** ជូនចំពោះក្រុមហ៊ុន និងសមាគម ដែលបានបរិច្ចាគថវិកា ជួយសាងសង់អាគារសិក្សា នៅក្នុងរាជធានីភ្នំពេញ ដូចមាននាម និងចំនួនទឹកប្រាក់ខាងក្រោម ៖

១-ក្រុមហ៊ុនសំណង់ EVG 3 D កសាងអាគារសិក្សា ០២ខ្នងមាន ១៤ បន្ទប់ នៅអនុវិទ្យាល័យឬស្សី ១០០ ខ្នង ចំណាយអស់ទឹកប្រាក់ ១២០.០០០ ដុល្លារអាមេរិក

២-សមាគម SFIVA " Sotoshu Fukusen-ji International Volunter Association " កសាងអាគារសិក្សាមួយខ្នងបន្ថែមទៀត នៅសាលាបឋមសិក្សាបរ៉ាម៉ីប៉ិតូ ចំណាយអស់ទឹកប្រាក់ចំនួន ២២.៩៨៧ ដុល្លារអាមេរិក ។

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងប្រតិភូ រាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរងរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩
នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
**ហ៊ុន សែន**

★ ★ ★

## អនុក្រឹត្យលេខ ៤៦២ អនក្រ.តត
## ស្តីពីការជូនមេដាយមាសការងារ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសឱ្យប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

## សំរេច

មាត្រា ១ ._ ត្រូវបានប្រគល់ មេដាយមាស ការងារ ជូនលោក KAZUO MURAKAMI ជាទីប្រឹក្សា JAPAN INTERNATIONAL COOPERATION AGENCY ប្រចាំមជ្ឈមណ្ឌលគ្រឿងចក្រធុនៗ ដែលបានខិតខំបំពេញការងារគាំទ្របច្ចេកទេសដ៏ល្អប្រសើរ ក្នុងពេលកម្ពុជាជំនាញការអោមជ្ឈមណ្ឌលការងារថែទាំ ( RCC ) នៃក្រសួងសាធារណការនិងដឹកជញ្ជូន ។

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩
នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
**ហ៊ុន សែន**

★ ★ ★

## អនុក្រឹត្យលេខ ៤៦៣ អនក្រ.តត

## ស្តីពីការជូនមេដាយមាសស្ថាបនាជាតិ

* * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាល វិជ្ជាជីវៈនិងយុវនីតិសម្បទា

### សំរេច

**មាត្រា ១ ._** ត្រូវបានប្រគល់ **មេដាយមាស ស្ថាបនាជាតិ** ជូនតំណាងអង្គការអន្តរជាតិ ដែលបានផ្តល់ការកសាងអគារស្នាក់នៅ ០២ ខ្នង និងអាគារសំរាប់ធ្វើផ្ទះបាយ ០១ខ្នងនៅបុរីកុមារ ក្រុងព្រះសីហនុ ដោយចំណាយទឹកប្រាក់សរុបអស់ចំនួន ៥២.០០០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោមនេះ ៖

១-តំណាងអង្គការ ASPECA

២-តំណាងអង្គការ UNESCO

**មាត្រា ២ ._** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងអភិបាលក្រុងព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★ ★ ★

# ២-សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៩៩

## សេចក្តីសំរេចលេខ ៥៤ សសរ

## ស្តីពីការបន្ថែមសមាសភាពសមាជិកគណៈកម្មការសំរាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសំរេចលេខ ០៧/សសរ/ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មការសំរាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា
- យោងតាមតម្រូវការរបស់គណៈកម្មការដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា

## សំរេច

**ប្រការ ១ :** ត្រូវបានបន្ថែមសមាសភាពគណៈកម្មការសំរាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា ដែលមានរាយនាមដូចខាងក្រោម ៖

១- ឯកឧត្តម ពោះ យ៉ាដា អនុរដ្ឋលេខាធិការ ក្រសួងព័ត៌មាន សមាជិក

២- ឯកឧត្តម អ៊ុំ ម៉ុនធឿន អនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ សមាជិក

៣- ឧត្តមសេនីយ៍ត្រី សុខ ផល ប្រធាននាយកដ្ឋានព័ត៌មានទូទៅ នៃក្រសួងមហាផ្ទៃ សមាជិក

**ប្រការ ២ :** សមាជិកគណៈកម្មការសំរាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬ អនុប្រធាន ។

**ប្រការ ៣ :** ទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មការដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា ក្រសួងព័ត៌មាន ក្រសួងវប្បធម៌ ក្រសួងមហាផ្ទៃ គ្រប់ក្រសួងស្ថាប័ន សាលាខេត្ត-ក្រុង ដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះចាប់ពី ថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★ ★ ★

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៩

# សេចក្តីសំរេចលេខ ៥៥ សសរ

## ស្តីពីការបង្កើតក្រុមការងារ សហប្រតិបត្តិការជាមួយអ្នកជំនាញច្បាប់បរទេស ដើម្បីរៀបចំនីតិវិធី សំរាប់កាត់ទោសឧក្រិដ្ឋជនខ្មែរក្រហម

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- ផ្អែកលើការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១ :** បង្កើតក្រុមការងារ សហប្រតិបត្តិការជាមួយអ្នកជំនាញច្បាប់បរទេសដើម្បីរៀបចំនីតិវិធីសំរាប់កាត់ទោសឧក្រិដ្ឋជនខ្មែរក្រហមដែលមានសមាសភាពដូចតទៅ ៖

| | | |
|---|---|---|
| ១- ឯកឧត្តម សុខ អាន | ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ជាប្រធាន |
| ២- ឯកឧត្តម អ៊ុក វិធុន | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | ជាអនុប្រធាន |
| ៣- ឯកឧត្តម ហេង វង្សប៊ុនឆាត | ឧត្តមទីប្រឹក្សារាជរដ្ឋាភិបាល | ជាអនុប្រធាន |
| ៤- ឯកឧត្តម ឱម យិនទៀង | ប្រធានគណៈកម្មការសិទ្ធិមនុស្សនៃរាជរដ្ឋាភិបាលកម្ពុជា | ជាអនុប្រធាន |
| ៥- លោកជំទាវ លី វុចឡេង | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ជាសមាជិក |
| ៦- ឯកឧត្តម ស៊ុយ នូ | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ជាសមាជិក |
| ៧- ឯកឧត្តម ឆាន់ តានី | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី | ជាសមាជិក |
| ៨- ឯកឧត្តម អង្គ វង្សវឌ្ឍនា | ទីប្រឹក្សាឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង | ជាសមាជិក |
| ៩- លោក ឡេង ម៉ើនឡុង | ប្រធានក្រុមជំនាញក្រុមប្រឹក្សាអ្នកច្បាប់ | ជាសមាជិក |

**ប្រការ ២ :** ក្រុមការងារនេះ មានភារកិច្ច

- សហការជាមួយអ្នកច្បាប់ ឬអ្នកបរទេស ពិចារណាអំពីនីតិវិធី ពិគ្រោះអំពីច្បាប់ និងបទដ្ឋានចាំបាច់ ដើម្បីបង្កើតតុលាការសំរាប់កាត់ទោសជនដែលជាប់ចោទ អំពីបទប្រល័យពូជសាសន៍ ។
- រៀបចំទីតាំង និងពិចារណាអំពីវិធានការដើម្បីរក្សាសណ្តាប់ធ្នាប់ និងរបៀបរៀបរយ ពេលតុលាការធ្វើសវនាការ ។

- សហការជាមួយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំពូលនៃអង្គចៅក្រម ដើម្បីសំរេចកិច្ចការខាងលើនេះ ។

**ប្រការ ៣ :** ប្រធានក្រុមការងារ អាចកោះប្រជុំនិងអញ្ជើញតំណាងស្ថាប័នផ្សេងទៀត ឬមន្ត្រីលេខាធិការ-ដ្ឋានអមក្រុមប្រឹក្សាកំពូលទីតាំង ក្រុម និងអង្គភាពផ្សេងៗ របស់ទីស្ដីការគណៈរដ្ឋមន្ត្រីដើម្បីសំរេចបេសកកម្មនេះ ។

**ប្រការ ៤ :** ប្រធានក្រុមការងារ ត្រូវរាយការណ៍អំពីដំណើរការនៃក្រុមការងារ ឬបញ្ហាដែលត្រូវដោះ-ស្រាយ ជូននាយករដ្ឋមន្ត្រី ព្រមទាំងធ្វើសេចក្ដីរាយការណ៍បញ្ចប់ ។

**ប្រការ ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌, រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃគ្រប់ក្រសួង និងអគ្គលេខាធិការដ្ឋានដែលពាក់ព័ន្ធព្រមទាំងអស់លោកជំទាវ និងលោកឧត្ដម ដែលមានរាយនាមក្នុងប្រការ ១ ត្រូវអនុវត្តសេចក្ដីសំរេចនេះចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★ ★ ★

# II- ការងារបណ្ដាក្រសួង

## ១-ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៩៩

**ប្រកាសលេខ ៣៤៧ ពណ.នគក.ប្រក**

**ស្ដីពីការត្រួតពិនិត្យការចុះបញ្ជីពាណិជ្ជកម្ម**

**តាមបណ្ដាខេត្ត- ក្រុង**

***

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតាត់តាំង នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៥ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើនូវ ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួង

## សំរេច

**ប្រការ ១ :** ប្រគល់ភារកិច្ចអោយមន្ត្រីនាយកដ្ឋាននីតិកម្ម នៃក្រសួងពាណិជ្ជកម្ម ចុះបំពេញការងារត្រួតពិនិត្យការចុះបញ្ជីពាណិជ្ជកម្មតាមខេត្ត-ក្រុង នានាក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ២ :** ភារកិច្ចរបស់មន្ត្រីទាំងនោះមានដូចតទៅ :

-ផ្សព្វផ្សាយនិងជំរុញបន្ថែមការអនុវត្តន៍ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មព្រមទាំងសារាចរណែនាំ ប្រកាសនិងសេចក្តីជូនដំណឹងនានា ស្តីពីការពាក់ព័ន្ធដល់ការចុះបញ្ជីពាណិជ្ជកម្ម ។

-សហការជាមួយមន្ត្រីមន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង និងអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ ក្តាប់ និងត្រួតស្ថិតិអោយបាននូវចំនួនពាណិជ្ជករ អាជីវករដែលជាប់ពន្ធលើប្រាក់ចំណេញ ក្រុមហ៊ុនពាណិជ្ជកម្ម ការិយាល័យតំណាងឬទីភ្នាក់ងារ សាខាក្រុមហ៊ុនបុគ្គលម្នាក់ ដែលបានចុះបញ្ជីពាណិជ្ជកម្មរួចហើយ និងកំពុងធ្វើសកម្មភាពពាណិជ្ជកម្មក្នុងមូលដ្ឋានខេត្ត-ក្រុងនីមួយៗ ។

-សហការជាមួយមន្ត្រីមន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង និងអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ ណែនាំ និងជំរុញដល់រាល់ពាណិជ្ជករអាជីវកម្មដែលជាប់ពន្ធលើប្រាក់ចំណេញ ក្រុមហ៊ុនពាណិជ្ជកម្ម ការិយាល័យតំណាងឬទីភ្នាក់ងារ សាខាក្រុមហ៊ុន បុគ្គលម្នាក់ដែលមិនទាន់បានចុះបញ្ជីពាណិជ្ជកម្ម អោយមកចុះបញ្ជីពាណិជ្ជកម្មស្របតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ។

-តំរូវដល់រាល់ពាណិជ្ជករ អាជីវករដែលជាប់ពន្ធលើប្រាក់ចំណេញ ក្រុមហ៊ុនពាណិជ្ជកម្ម ការិយាល័យតំណាង ឬទីភ្នាក់ងារសាខាក្រុមហ៊ុន បុគ្គលម្នាក់ ដែលកំពុងធ្វើសកម្មភាពពាណិជ្ជកម្មអោយបំពេញប្រតិវេទន៍អំពីស្ថានភាពសហគ្រាសពាណិជ្ជកម្មប្រចាំឆ្នាំ ។

**ប្រការ ៣ :** នាយកដ្ឋាននីតិកម្ម និងមន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង ត្រូវសហការពិតស្និទ្ធជាមួយអាជ្ញាធរដែនដី ដើម្បីរៀបចំជាផែនការលំអិតសំរាប់អនុវត្តតាមត្រីមាសនីមួយៗ និងសេចក្តីជូនដំណឹងនានាដែលពាក់ព័ន្ធដល់ការងារត្រួតពិនិត្យ ការចុះបញ្ជីពាណិជ្ជកម្មនេះ ដើម្បីទទួលបាននូវលទ្ធផលប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

**ប្រការ ៨ :** អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គាធិការដ្ឋាន និងមន្ទីរពាណិជ្ជកម្មខេត្ត-ក្រុងទាំងអស់ត្រូវអនុវត្តអោយមានប្រសិទ្ធភាពខ្ពស់តាមស្មារតីនៃប្រកាសនេះ ។

**ប្រការ ៩ :** ប្រកាសនេះមានអនុភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ចម ប្រសិទ្ធ**

★ ★ ★

## ២-នីតិការរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៩

**ប្រកាសលេខ១៨៤ ធសប្រក**
**ស្តីពីការបង្កើតមន្ទីរធម្មការនិងសាសនា**
**ខេត្ត ឧត្តរមានជ័យ**

***

**រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/១០៩៥/០៧ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតខេត្តឧត្តរមានជ័យ របស់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅ នៃក្រសួងធម្មការ និង សាសនា
- បានឃើញលិខិតលេខ ០៥៩ សឧឧជ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ១៩៩៩ របស់សាលាខេត្តឧត្តរមានជ័យ
- អនុលោមតាមការងារចាំបាច់របស់ក្រសួង

**សំរេច**

**ប្រការ ១ :** បង្កើតមន្ទីរធម្មការ និងសាសនា ខេត្តឧត្តរមានជ័យ ដែលមានអង្គភាពចំណុះ ៤ ÷

-ការិយាល័យរដ្ឋបាល- ការិយាល័យធម្មការ និងសាសនា ការិយាល័យពុទ្ធិកសិក្សា និងបណ្ណាល័យ (ថ្នាក់ស្មើការិយាល័យ) និងការិយាល័យធម្មការ និងសាសនាស្រុកទាំង ៥ ÷

១-ការិយាល័យធម្មការ និងសាសនា ស្រុកសំរោង

២-ការិយាល័យធម្មការ និងសាសនា ស្រុកបុទុមសាគរ

៣-ការិយាល័យធម្មការ និងសាសនា ស្រុក គិរីសាគរ

៤-ការិយាល័យធម្មការ និងសាសនា ស្រុក ស្រែអំបិល

៥-ការិយាល័យធម្មការ និងសាសនា ស្រុក មណ្ឌលសីមា

សរុបមាន ២១ កន្លែង និង២១ ក្របខ័ណ្ឌ

**ប្រការ ២ :** មន្ទីរធម្មការនិងសាសនាមានប្រធានមន្ទីរម្នាក់ និងអនុប្រធានមន្ទីរម្នាក់ជំនួយការ ។ ស្រុកនីមួយៗ មានប្រធានការិយាល័យ ស្រុកម្នាក់ជាអ្នកដឹកនាំ ។

**ប្រការ ៣ :** ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ គណៈកម្មការខេត្តក្រុងពាក់ព័ន្ធ មន្ទីរធម្មការនិងសាសនា មន្ទីរផែនការ មន្ទីរហិរញ្ញវត្ថុខេត្តក្រុងពាក់ព័ន្ធ ត្រូវទទួលការអនុវត្តតាមសេចក្តីប្រកាសនេះ ។

**ប្រការ ៤ :** ប្រកាសនេះមានអានុភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ជា សាវឿន**

★ ★ ★